**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកណ្តាល**

សំណុំរឿងព្រហ្មទណ្ឌ
លេខ ៩០៩ អ.ក
ចុះថ្ងៃទី ៣០.មិថុនា.២០២២
សាលក្រមលេខ:៣៦"ណ"
ចុះថ្ងៃទី ១៤ ខែ មីនា ២០២៣

## **តាមនាមប្រជារាស្ត្រខ្មែរ**

សាលាដំបូងខេត្តកណ្តាល បានបើកសវនាការជាសាធារណៈ នាថ្ងៃទី១៤ ខែ មីនា ឆ្នាំ ២០២៣ ដោយមានសមាសភាពដូចតទៅ៖

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ប្រធានក្រុមប្រឹក្សាជំនុំជម្រះ
លោកស្រី ចៅក្រមប្រឹក្សា
លោក ចៅក្រមប្រឹក្សា

**តំណាងអយ្យការ**

លោក [redacted] ជាព្រះរាជអាជ្ញារង

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted] ជាក្រឡាបញ្ជី

## **ដើម្បីជំនុំជម្រះ**

លើសំណុំរឿងព្រហ្មទណ្ឌលេខ ៩០៩ អ.ក ចុះថ្ងៃទី ៣០.មិថុនា ២០២២ ដែល មានជនជាប់ចោទ:

១.ឈ្មោះ [redacted] **សម្ផស្ស** ភេទ ប្រុស អាយុ២៧ឆ្នាំ ជនជាតិខ្មែរ កម្រិតវប្បធម៌ថ្នាក់ទី១២ មុខរបរមិនពិតប្រាកដ មានទីកន្លែងកំណើត ភូមិ [redacted] ខេត្ត កណ្តាល ទីលំនៅបច្ចុប្បន្ន ភូមិ [redacted] ខេត្ត កណ្តាល។ ឪពុកឈ្មោះ [redacted] **ប៊ិន** (រស់) ម្តាយឈ្មោះ [redacted] **ទុំ** (រស់) ប្រពន្ធឈ្មោះ [redacted] **ឡៃ** មានកូន ០៣នាក់ ជានីតិជន ទោសពីមុនគ្មាន។ (ក្នុងឃុំ)

២.ឈ្មោះ [redacted] **កុសល់** ភេទ ប្រុស អាយុ៣២ឆ្នាំ សញ្ជាតិខ្មែរ កម្រិតវប្បធម៌ថ្នាក់ទី៨ មុខរបរ មិនពិតប្រាកដ មានទីកន្លែងកំណើត និង ទីលំនៅបច្ចុប្បន្ន ភូមិ [redacted] ខេត្ត កណ្តាល ឪពុកឈ្មោះ [redacted] **ឌុន**(រស់) ម្តាយឈ្មោះ [redacted] **ស្រី**(រស់) នៅលីវ ជានីតិជន ទោសពីមុនគ្មាន ។ (គេចខ្លួន)

ជាប់ចោទពីបទ: **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅ ភូមិ ព្រែកតាកូវ ឃុំព្រែកតាកូវ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល កាលពីថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ២០២២ តាមមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

***អង្គហេតុនៃរឿងមានដូចតទៅ៖***

កាលពីថ្ងៃទី ២៩ ខែមិថុនា ឆ្នាំ២០២២ វេលាម៉ោង១៦ និង២០នាទី មានករណីជួញដូរដោយខុសច្បាប់នូវសារធាតុញៀន បានកើតឡើងនៅភូមិព្រែកតាកូវ ឃុំព្រែកតាកូវ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ប្រព្រឹត្តឡើងដោយជនជាប់ចោទឈ្មោះ [redacted] **សម្ផស្ស** ជាមុខ



Scanned with CamScanner

សញ្ញាជួញដូរថ្នាំញៀនយ៉ាងសកម្មនៅក្នុងមូលដ្ឋានក្នុងស្រុកខ្សាច់កណ្តាលដែលជនជាប់ចោទ ឈ្មោះ [redacted] សម្ផស្សបានឡើងទៅទិញថ្នាំញៀន ប្រភេទម៉ាទឹកកកពីជនជាប់ចោទឈ្មោះ [redacted] កុសល់ម្តងៗ បានចំនួន០១កញ្ចប់ តម្លៃ៣០ម៉ឺនរៀលហើយបានយកមករំលែកជា កញ្ចប់តូចៗ ទុកលក់ឱ្យម៉ូយនៅក្នុងភូមិ តម្លៃ១៥,០០០ (មួយម៉ឺនប្រាំពាន់រៀល) ក្នុង០១កញ្ចប់ ដោយលក់ចំណេញបានលុយម្តងៗ គឺទុកសម្រាប់ចាយ និងបន្សល់ ថ្នាំញៀនខ្លះ សម្រាប់ ប្រើប្រាស់ខ្លួនឯង។ ពេលត្រឡប់មកពីថ្នាំញៀនប្រភេទម៉ាទឹកកក ខ្ញុំបានដើរតាមផ្លូវតម្រង់មកផ្ទះវិញ ក៏ប្រទះសមត្ថកិច្ចកំពុងល្បាតដោយមានការសង្ស័យ សមត្ថកិច្ចបានធ្វើ ការឆែកឆេរក៏បានរកឃើញថ្នាំញៀនប្រភេទម៉ាទឹកកក០១កញ្ចប់ធំ មានទម្ងន់៣៧.៣៦ក្រាម និងជញ្ជីងថ្លឹងគ្រឿងញៀនចំនួន០១ ហើយសមត្ថកិច្ចបានធ្វើការឃាត់ខ្លួនជនជាប់ចោទ ព្រមទាំងវត្ថុតាង មកអធិការដ្ឋាននគរបាលស្រុកខ្សាច់កណ្តាល ដើម្បីចាត់ការតាមនីតិវិធី។

**បានឃើញ** ដីកាដំណោះស្រាយលេខៈ ១២៥៤ ដកដស ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០២២ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកណ្តាល។

**បានឃើញ** ដីកាចាត់តាំងប្រធានក្រុមប្រឹក្សាជំនុំជម្រះលេខៈ ១៣៣៥ ដកចត ចុះថ្ងៃទី០៣ ខែ វិច្ឆិកា ឆ្នាំ ២០២២។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] **សម្ផស្ស** ឆ្លើយថាៈ កាលពីថ្ងៃទី ២៩ ខែមិថុនា ឆ្នាំ២០២២ វេលាម៉ោង១៦ និង២០នាទី ខ្លួនបានឡើងទៅទិញថ្នាំញៀនប្រភេទម៉ាទឹកកកពីជនជាប់ចោទឈ្មោះ [redacted] **កុសល់** ភេទ ប្រុស អាយុ៣២ឆ្នាំ រស់នៅភូមិព្រែកបង្កង ឃុំព្រែកតាកូវ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ដោយទិញ បានចំនួន០១កញ្ចប់ តម្លៃ៣០ម៉ឺន ទិញនៅមុំមាត់ទន្លេ ផ្ទះរបស់ជនជាប់ចោទ ឈ្មោះ [redacted] **កុសល់**។ ក្រោយពីទិញរួច ខ្លួនបានយកថ្នាំញៀនមករំលែកជាកញ្ចប់តូចៗទុកសម្រាប់លក់ឱ្យម៉ូយនៅក្នុងភូមិ ដោយលក់ ក្នុងតម្លៃ១៥,០០០៛ (មួយម៉ឺនប្រាំពាន់រៀល) ក្នុង០១កញ្ចប់ ប្រាក់ដែលបានមកពីការលក់ថ្នាំញៀនគឺខ្លួនទុកសម្រាប់ចាយវាយ ហើយនិងបន្សល់ទុក ថ្នាំញៀនខ្លះទៀត សម្រាប់ប្រើប្រាស់ខ្លួនឯងហើយកន្លងមកខ្លួនក៏ធ្លាប់បានលក់គ្រឿងញៀនឱ្យអ្នកនៅក្នុងភូមិជាមួយគ្នា៣ទៅ៤ដងដែរ។ នៅថ្ងៃកើតហេតុ នៅពេលដែលខ្លួន ត្រឡប់មកពីទិញថ្នាំញៀន ប្រភេទម៉ាទឹកកក ហើយជិះម៉ូតូធ្វើដំណើរតាមផ្លូវត្រឡប់មកផ្ទះវិញនោះ ក៏ប្រទះសមត្ថកិច្ចកំពុងល្បាត ដោយមានការសង្ស័យ សមត្ថកិច្ចក៏បានធ្វើ ការឆែកឆេរ រកឃើញថ្នាំញៀនប្រភេទម៉ាទឹកកកចំនួន ០១កញ្ចប់ធំ មានទម្ងន់៣៧.៣៦ក្រាម និងជញ្ជីងថ្លឹងគ្រឿងញៀន ចំនួន០១(មួយ)។

-អានកំណត់ហេតុទទួលវត្ថុតាងថាៈ មានម្សៅក្រាមពណ៌សថ្លាសង្ស័យជាសារធាតុញៀន ប្រភេទម៉ាទឹកកក ចំនួន០១ កញ្ចប់តូច វេចខ្ចប់ដាក់ក្នុងស្រោមសំបុត្រធំ ចំនួន០២ពណ៌តគី គ្មានលេខកូដ, ទូរស័ព្ទដៃចំនួន ១គ្រឿង ម៉ាកOPPO ពណ៌លឿង មិនដំណើរការ)។



Scanned with CamScanner

-អានកំណត់ហេតុធ្វើតេស្តបឋម និង វេចខ្ចប់វត្ថុតាងថា: ដំណើរការថ្លឹង ឃើញមានទម្ងន់៣៧,៣៦ក្រាម បានសាកល្បងធ្វើតេស្តលើវត្ថុតាងម្សៅក្រាមពណ៌សថ្លា ដោយប្រើឧបករណ៍ (MARQUIS TEST ) ឃើញលទ្ធផលប្រែពណ៌ស ទៅជាពណ៌ទឹកក្រូច គឺមានសារធាតុមេតំហ្វេតាមីន ។

-អានលទ្ធផលកោសលវិច័យគ្រឿងញៀន បានបញ្ជាក់ថា: លទ្ធផលវិជ្ជមាន ,វត្ថុមានសារធាតុញៀន ឈ្មោះ មេតំហ្វេតាមីន (Methamphetamine), បរិមាណសារធាតុ មេតំហ្វេតាមីនគិតជា ភាគរយនៃទម្ងន់គឺ៖ ៧៣.៥៧% (ចិតសិបបីកណ្តក់សញ្ញាហាសិបប្រាំ ពីរភាគរយ)។

-តំណាងអយ្យការសន្និដ្ឋាន:មានភស្តុតាងលើជនជាប់ចោទ ពីបទ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** លើជនជាប់ចោទឈ្មោះ [redacted] **សម្ផស្ស** និង [redacted] **កុសល់** ប្រព្រឹត្តនៅ ភូមិ ព្រៃកតាកូវ ឃុំព្រៃកតាកូវ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល កាលពីថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ២០២២ តាមមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

-លោកមេធាវី [redacted] ការពារសិទ្ធិឱ្យជនជាប់ចោទ ឈ្មោះ [redacted] **សម្ផស្ស** និង **ឌឹម កុសល់** បានធ្វើសេចក្តីសន្និដ្ឋានថា: ស្នើសុំឱ្យតុលាការជួយបន្ធូរបន្ថយទោស។

ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

**ក្រោយពីបានថយទៅពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ**

## យល់ឃើញថា:

**ក.ពិរុទ្ធភាព៖**

១-តាមដីកាដំណោះស្រាយលេខ ១២៥៤ ដកដស ចុះថ្ងៃទី៣០ ខែ តុលា ឆ្នាំ ២០២២ បានសម្រេចបញ្ជូន ជនជាប់ចោទ ឈ្មោះ [redacted] **សម្ផស្ស** និង [redacted] **កុសល់** ពីបទ: **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅ ប្រព្រឹត្តនៅ ភូមិ ព្រៃកតាកូវ ឃុំព្រៃកតាកូវ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល កាលពីថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ២០២២ តាមមាត្រា ៤០ នៃច្បាប់ស្តីពីការ ត្រួតពិនិត្យគ្រឿងញៀនទៅជំនុំជម្រះ។

២-តាមចម្លើយរបស់ជនជាប់ចោទបានឱ្យដឹងថា: កាលពីថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០២២ វេលាម៉ោង១៦ និង២០នាទី ខ្លួនបានឡើងទៅទិញថ្នាំញៀនប្រភេទម៉ាទឹកកក ពីជនជាប់ចោទឈ្មោះ [redacted] **កុសល់** ភេទ ប្រុស អាយុ ៣២ឆ្នាំ រស់នៅភូមិព្រៃកបង្កង ឃុំព្រៃកតាកូវ ស្រុកខ្សាច់ កណ្តាល ខេត្តកណ្តាល ដោយទិញបានចំនួន០១កញ្ចប់ តម្លៃ ៣០ម៉ឺន ទិញនៅ មុំមាត់ទន្លេផ្ទះរបស់ជនជាប់ចោទ ឈ្មោះ [redacted] **កុសល់** ។ ទិញរួចហើយខ្លួនបានយកថ្នាំញៀនមករំលែកជាកញ្ចប់តូចៗទុកសម្រាប់លក់ឱ្យម៉ូយនៅក្នុងភូមិ ក្នុងតម្លៃ១៥,០០០ (មួយម៉ឺនប្រាំពាន់រៀល) ក្នុង០១កញ្ចប់ ដោយលក់បានលុយម្តងៗ គឺខ្លួនទុកសម្រាប់ចាយវាយ និងទុកថ្នាំញៀនខ្លះសម្រាប់ ប្រើប្រាស់ខ្លួនឯង។ នៅពេលខ្លួនត្រឡប់មកពីទិញថ្នាំញៀន ប្រភេទម៉ាទឹកកក ខណ:ដែលខ្លួន កំពុងជិះម៉ូតូធ្វើដំណើរតាមផ្លូវតម្រង់មកផ្ទះវិញនោះ ក៏ប្រទះនឹងសមត្ថកិច្ចកំពុងល្បាត ដោយមានការសង្ស័យ



Scanned with CamScanner

សមត្ថកិច្ចក៏បានធ្វើ ការឆែកឆេរ រកឃើញថ្នាំញៀនប្រភេទម៉ាទឹកកកចំនួន០១កញ្ចប់ធំ មានទម្ងន់៣៧.៣៦ក្រាមចម និងជញ្ជីងថ្លឹងគ្រឿងញៀន ចំនួន០១(មួយ)។

៣-កំណត់ហេតុធ្វើតេស្តបឋម និង វេចខ្ចប់វត្ថុតាងថា: ដំណើរការថ្លឹង ឃើញមានទម្ងន់៣៧,៣៦ក្រាម បានសាកល្បងធ្វើតេស្តលើវត្ថុតាងម្សៅក្រាមពណ៌សថ្លា ដោយប្រើឧបករណ៍ (MARQUIS TEST ) ឃើញលទ្ធផលប្រែពណ៌ស ទៅជាពណ៌ទឹកក្រូច គឺមានសារធាតុមេតំហ្វេតាមីន ។

៤-លទ្ធផលកោសលវិច័យគ្រឿងញៀន បានបញ្ជាក់ថា: លទ្ធផលវិជ្ជមាន ,វត្ថុមានសារធាតុញៀន ឈ្មោះ មេតំហ្វេតាមីន (Methamphetamine), បរិមាណសារធាតុមេតំហ្វេតាមីនគិត ជាភាគរយនៃទម្ងន់ គឺ៖៧៣.៥៧% (ចិតសិបបីកណ្តុក់សញ្ញាហាសិប ប្រាំពីរភាគរយ)។

៥-តំណាងអយ្យការសន្និដ្ឋាន: មានភស្តុតាងលើជនជាប់ចោទ ពីបទ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** លើជនជាប់ចោទឈ្មោះ [redacted] **សម្ផស្ស** និង [redacted] **កុសល់** ប្រព្រឹត្តនៅ ភូមិ ព្រៃកតាកូវ ឃុំព្រៃកតាកូវ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល កាលពីថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ២០២២ តាមមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៦-លោកមេធាវី [redacted] ការពារសិទ្ធិឱ្យជនជាប់ចោទ ឈ្មោះ [redacted] **សម្ផស្ស** និង **ឌឹម កុសល់** បានធ្វើសេចក្តីសន្និដ្ឋានថា: ស្នើសុំឱ្យតុលាការជួយបន្ធូរបន្ថយទោស។

៧-ជនជាប់ចោទឈ្មោះ [redacted] **សម្ផស្ស** និង [redacted] **កុសល់** ដោយតាមចម្លើយ សារភាពរបស់ជនជាប់ចោទ នៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌, ដំណាក់កាលអយ្យការ, ដំណាក់កាលចៅក្រមស៊ើបសួរ និងចម្លើយសារភាពរបស់ជនជាប់ចោទនៅ ក្នុងដំណាក់កាលជំនុំជម្រះមានភាពស៊ីសង្វាក់គ្នាដែលអាចបញ្ជាក់បានថានៅថ្ងៃកើតហេតុ ជនជាប់ចោទឈ្មោះ [redacted] **សម្ផស្ស** និង [redacted] **កុសល់** ពិតបានជួញដូរគ្រឿងញៀន ប្រាកដមែន។

៨-អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] **សម្ផស្ស** និង [redacted] **កុសល់** បានធ្វើឲ្យប៉ះពាល់ដល់សុខភាពមនុស្សជាតិ និង របៀបរៀបរយសាធារណៈ និង សណ្តាប់ធ្នាប់សង្គម។ ជាសារធាតុដែលត្រូវបានច្បាប់ហាមឃាត់ ។ ដូចនេះ ត្រូវតែទទួល ខុសត្រូវ ចំពោះមុខច្បាប់ ។

៩-ជនជាប់ចោទ ឈ្មោះ [redacted] **សម្ផស្ស** និង [redacted] **កុសល់** ជាសមត្ថជន ដែលអាចយល់ដឹងពីបច្ច័យ ដែលកើតឡើងពីអំពើរបស់ខ្លួនបាន។

១០-មានភស្តុតាង បញ្ជាក់ពីពិរុទ្ធលើជនជាប់ចោទ ឈ្មោះ [redacted] **សម្ផស្ស** និង [redacted] **កុសល់** ពីបទ: **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្ត ភូមិព្រៃកតាកូវ ឃុំព្រៃកតាកូវ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល កាលពីថ្ងៃទី ២៩ ខែមិថុនា ឆ្នាំ២០២២ តាមមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

**ខ.អំពីវត្ថុចាប់យក**

**១.**សារធាតុញៀនឈ្មោះ មេតំហ្វេតាមីន (Methamphetamine) បរិមាណសារធាតុមេតំហ្វេ តាមីន គិតជាភាគរយ នៃទម្ងន់គឺ ៧៣.៥៧%(ចិតសិបបីកណ្តុក់សញ្ញាហាសិបប្រាំពីរ ភាគរយ) ចំនួន០១កញ្ចប់ធំ,ទូរស័ព្ទដៃចំនួន១គ្រឿង ម៉ាក OPP ពណ៌លឿង (មិនដំណើរការ)។

២.ទូរស័ព្ទដៃ ចំនួន១គ្រឿង ម៉ាក OPPO ពណ៌លឿងគប្បីតុលាការសម្រេចរឹបអូស ។



Scanned with CamScanner

គ.អំពីទោសៈ

**ហេតុដូច្នេះ-តុលាការ**

**<u>សម្រេច</u>**

**១.ផ្តន្ទាទោសលើ**

ក.ជនជាប់ចោទឈ្មោះ [redacted] **សម្ផស្ស** (មានសាវតារជាតិគ្រប់គ្រាន់ដូចខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេល ៦ (ប្រាំមួយ) ឆ្នាំ ។

ខ.ជនជាប់ចោទឈ្មោះ [redacted] **កុសល់** (មានសាវតារជាតិគ្រប់គ្រាន់ដូចខាងលើ)ដាក់ពន្ធនាគារកំណត់រយៈពេល ៦ (ប្រាំមួយ) ឆ្នាំ និងពិន័យជាប្រាក់ចំនួន ១០,០០០,០០០ (ដប់លាន) រៀល។

ពីបទៈ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិព្រែកតាកូវ ឃុំព្រែកតាកូវ ស្រុក ខ្សាច់កណ្តាល ខេត្តកណ្តាល កាលពីថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ២០២២ តាម មាត្រា ៤០ កថាខណ្ឌ ទី ៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

**២.វត្ថុតាងមានៈ**

ក.សារធាតុញៀនឈ្មោះ មេតំហ្វេតាមីន (Methamphetamine) បរិមាណសារធាតុមេតំហ្វេតាមីន គិតជាភាគរយនៃទម្ងន់សរុប គឺ៧៣.៥៧%(ចិតសិបបីកណ្តាក់សញ្ញាហាសិបប្រាំពីរភាគរយ) ត្រូវរឹបអូសបំផ្លាញចោល។

ខ.ទូរស័ព្ទដៃ ចំនួន១គ្រឿង ម៉ាក OPPO ពណ៌លឿង ត្រូវរឹបអូសជាសម្បត្តិរដ្ឋ។

សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០២៣ និង ប្រកាសជាសារ ធារណៈ នៅថ្ងៃទី២១ ខែ មីនា ឆ្នាំ ២០២៣ ចំពោះមុខជនជាប់ចោទ ឈ្មោះ [redacted] **សម្ផស្ស** និង កំបាំងមុខជនជាប់ចោទ ឈ្មោះ [redacted] កុសល់ទុកសិទ្ធិប្តឹងទាស់ និង ប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមប្រឹក្សា** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សា** |
| --- | --- | --- | --- |
| [redacted] | | [redacted] | [redacted] |

**បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម**

ថ្ងៃទី១៤ ខែ៣ ឆ្នាំ ២០២៣

**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner